CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២៧ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# គ្រឹះស្ថាននៅទីក្រុងឡុងប៊ិចបន្ថែមអាចនឹងបើកដំណើរការឡើងវិញដោយមានការដាក់កម្រិតខ្លះ

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះទីក្រុងឡុងប៊ិចបានប្រកាសថាការិយាល័យផ្សេងៗ ព្រះវិហារនិងកន្លែងគោរពបូជា ហើយនិងហាងទំនិញដែលអាចចូលទិញដោយផ្ទាល់បាននឹងអាចបើកជាថ្មីដោយមានការដាក់កម្រិតខ្លះស្របតាមរដ្ឋកាលីហ្វ័រញ៉ានិងខោនធី Los Angeles។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ហាងទំនិញនិងហាងលក់សំលៀកបំពាក់តូចៗនិងកន្លែងគោរពបូជារបស់យើងត្រូវការការគាំទ្រពីយើងហើយដល់ពេលដែលកន្លែងទាំងនេះត្រូវបើកឡើងវិញដោយសុវត្ថិភាព។ យើងបន្តមើលឃើញទិន្នន័យដែលគួឱ្យលើកទឹកចិត្តនៅឡុងប៊ិចហើយយើងនឹងបន្តដំណើរការទៅមុខដោយប្រុងប្រយ័ត្ន។"

ដោយសារបទបញ្ជារក្សាសុវត្ថិភាពដោយនៅផ្ទះត្រូវបានកែប្រែគឺចាំបាច់ណាស់ដែលត្រូវចាត់វិធានការទាំងអស់ដើម្បីធានាសុវត្ថិភាពដល់បុគ្គលិក អ្នកស្ម័គ្រចិត្ត និងសាធារណជន។ បទបញ្ជាដែលបានកែសំរួលរាបរាប់លំអិតអំពីតំរូវការនិងការដាក់កម្រិតផ្សេងៗក្នុងគោលបំណងជួយទប់ស្កាត់ការរាលដាលនៃ COVID-19។ គ្រឹះស្ថានត្រូវអនុវត្តនិងបិទប្រកាសពីពិធីសាររក្សាចម្ងាយរាងកាយពីគ្នាមុនពេលបើកជាថ្មី។

**រាល់ប្រតិបត្តិការលក់ទំនិញនៅក្នុងហាងនិងអាជីវកម្មដែលមានមូលដ្ឋាននៅការិយាល័យត្រូវតែ៖**

- រក្សាចម្ងាយរាងកាយពីគ្នាក្នុងកំរិតអតិបរមាដែលអាចធ្វើបានរួមមាន៖
    - ហាងអាចបើកបានតែ ៥០% នៃចំណុះអតិបរមាតែប៉ុណ្ណោះ។
    - អាជីវកម្មដែលមានមូលដ្ឋាននៅការិយាល័យត្រូវបានលើកទឹកចិត្តឱ្យផ្តល់អាទិភាពដល់ការធ្វើការពីផ្ទះឬទូរគមនាគមន៍។
- អនុវត្តពិធីសារលាងសំអាតនិងបំបាត់មេរោគរួមទាំងការលាងដៃជាញឹកញាប់។
- តម្រូវឱ្យពាក់ម៉ាស់ពេលនៅក្បែរអ្នកដទៃ។
- រក្សាឱ្យស្ថិតស្ថេរនូវដំណើរការដើម្បីកំណត់ករណីជំងឺនិងធ្វើអន្តរាគមន៍យ៉ាងឆាប់រហ័ស។
- រៀបចំផែនការជាក់លាក់នៅកន្លែងធ្វើការសម្រាប់ប្រតិបត្តិការក្នុងគ្រាអាសន្នសុខភាពសាធារណៈនេះហើយបណ្តុះបណ្តាលបុគ្គលិកអំពីផែនការទាំងនេះ។

**កន្លែងគោរពបូជាទាំងអស់គឺតម្រូវឲ្យ៖**

- កំណត់ការចូលរួមដល់ ២៥% នៃចំណុះអគារឬចំនួនអ្នកចូលរួមដល់អតិបរមា ១០០ នាក់ (ណាមួយទាបជាង)។
- បញ្ឈប់សេវាកម្មទៅយកខ្លួនឯងនៃអាហារនិងភេសជ្ជៈ។
- ឈប់ទទួលទានអាហាររួមគ្នាដោយចែករំលែកអាហារឬបរិភោគបែបលក្ខណៈគ្រួសារ។ ទាំងនេះមិនត្រូវអនុញ្ញាតទេ។

ខោនធី Los Angeles បានដាក់ពាក្យសុំបំរែបំរួលដើម្បីឈានទៅដំណាក់កាលទី ២ ដោយបំណងឈានទៅដំណាក់កាលទី ៣។ នៅពេលបច្ចុប្បន្នឡុងប៊ិចត្រូវបានបញ្ចូលទៅក្នុងពាក្យសុំនោះដែរហើយនឹងអាចមានសិទ្ធិអនុញ្ញាតឱ្យភោជនីយដ្ឋាននិងហាងអ៊ុតសក់បើកដំណើរការឡើងវិញដោយមានការយល់ព្រមពីរដ្ឋនិងបទបញ្ជាសុខភាពជាបន្តបន្ទាប់។

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និងយោងទៅតាម អំណាចបន្ទាន់ (Emergency Powers) ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។ បទបញ្ជាទាំងនេះមានប្រសិទ្ធភាពភ្លាមៗនៅថ្ងៃទី ២៧ ខែឧសភាឆ្នាំ ២០២០ ហើយនឹងបន្តរហូតដល់ត្រូវបានពន្យារពេល ដកហូតវិញ ឬ

កែប្រែជាលាយលក្ខណ៍អក្សរដោយមន្ត្រីសុខាភិបាល។ បទបញ្ជាសុខភាពដែលត្រូវបានកែប្រែរួមបញ្ចូលទាំងការផ្លាស់ប្តូរផ្សេងទៀតដើម្បីអនុលោមតាមផែនទីបង្ហាញផ្លូវភាពរឹងមាំរបស់ខោនធីនិងកាលីហ្វ័រញ៉ាសម្រាប់ដំណាក់កាលទី ២ ដែលទាក់ទងទៅនឹងក្បួនដង្ហែរតាមយានយន្ត ផ្សារទំនើប សេវាកម្មសាសនា និងពិធីវប្បធម៌។ អាងហែលទឹកដែលមានទីតាំងស្ថិតនៅក្នុងលំនៅដ្ឋានពហុឯកជនឬជាផ្នែកមួយនៃសមាគមម្ចាស់ផ្ទះ (homeowner's association) អាចបើកដោយមានការរក្សាចម្ងាយរាងកាយពីគ្នា។ ប្រតិបត្តិការតាមឡានរួមទាំងការកម្សាន្តនិងភោជនីយដ្ឋាននឹងត្រូវអនុញ្ញាតឱ្យបើកឡើងវិញបាន ប៉ុន្តែត្រូវតែមានលិខិតអនុញ្ញាតដែលចេញដោយទីក្រុង។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

\# \# \#